## កិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៦
## រាជធានីភ្នំពេញ ថ្ងៃទី២៣-២៥ ខែសីហា ឆ្នាំ២០១៧

---

# សេចក្តីប្រកាសព័ត៌មាន

តបតាមការអញ្ជើញរបស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា ឧត្តមសេនីយ៍ **អានុភុង ផៅចិន្តា** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រថៃ បានមកបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជា និងដឹកនាំគណៈប្រតិភូថៃចូលរួមកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៦ នាថ្ងៃទី២៣-២៥ ខែសីហា ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ។

ក្នុងអំឡុងពេលនៃកិច្ចប្រជុំ ឧត្តមសេនីយ៍ **អានុភុង ផៅចិន្តា** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រថៃ បានចូលជួបសម្តែងការគួរសមជាមួយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងបានទៅទស្សនកិច្ចនៅសារៈមន្ទីរជាតិ។

កិច្ចប្រជុំបានដំណើរការដោយរលូន ស្របទៅតាមរបៀបវារៈ និងកម្មវិធីដែលបានគ្រោងទុកក្នុងបរិយាកាសមិត្តភាព សាមគ្គីភាព ភាតរភាព និងយោគយល់គ្នាទៅវិញទៅមក។ ភាគីទាំងពីរបានបង្ហាញនូវការយល់ឃើញរួមគ្នាអំពីសារៈសំខាន់នៃទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ដែលបានរួមចំណែកយ៉ាងសំខាន់នៅក្នុងការពង្រឹងពង្រីកចំណងទំនាក់ទំនងជាមិត្តភាព សាមគ្គីភាពជាប្រពៃណីរវាងប្រទេសទាំងពីរឲ្យកាន់តែរីកចម្រើន និងកាន់តែស៊ីជម្រៅថែមទៀត។ ភាគីទាំងពីរបានបង្ហាញសេចក្តីសោមនស្សរីករាយ និងបានសំដែងនូវបំណងដូចគ្នាក្នុងការបន្តរក្សានូវចំណងទាក់ទងជាប្រទេសជិតខាងល្អនឹងគ្នា ព្រមទាំងខិតខំកសាង និងថែរក្សាការពារឲ្យបាននូវព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងមានការអភិវឌ្ឍប្រកបដោយចីរភាព។

កិច្ចប្រជុំបានសង្កត់ធ្ងន់ទៅលើការពង្រឹងកិច្ចសហប្រតិបត្តិការរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ទៅលើបញ្ហាផ្សេងៗដូចខាងក្រោម៖

**១-<u>ការឆ្លងកាត់ព្រំដែន៖</u>** ភាគីទាំងពីរទទួលស្គាល់អំពីសារៈសំខាន់នៃការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការឆ្លងកាត់ព្រំដែនរវាងប្រទេសទាំងពីរ ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៥។ ភាគីទាំងពីរឯកភាពក្នុងការជំរុញឲ្យអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ និងប្រជាពលរដ្ឋនៃប្រទេសនីមួយៗប្រើប្រាស់នូវប័ណ្ណព្រំដែន ស្របតាមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការឆ្លងកាត់ព្រំដែន ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនៃប្រទេសនីមួយៗ ដើម្បីជួយសម្រួលដល់ការចេញចូលឆ្លងកាត់ព្រំដែនរបស់ប្រជាពលរដ្ឋរស់នៅតាមបណ្តាខេត្តជាប់ព្រំដែននៃប្រទេសទាំងពីរ និងទប់ស្កាត់ការចេញចូលឆ្លងកាត់ព្រំដែនដោយខុសច្បាប់។

**២-<u>ពាណិជ្ជកម្ម និងការវិនិយោគ៖</u>** កិច្ចប្រជុំមានការពេញចិត្តចំពោះកំណើននៃទំហំពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរដែលបានកើនឡើងដល់ជាង ៥ប៊ីលានដុល្លារអាមេរិកតាំងពីឆ្នាំ២០១៤មក ដែល

ក្នុងនោះទំហំពាណិជ្ជកម្មទ្វេភាគីប្រមាណ ៧០% ទទួលបានមកពីការផ្លាស់ប្តូរពាណិជ្ជកម្មតាមតំបន់ព្រំដែន។ ទន្ទឹមនេះ កិច្ចប្រជុំបានឯកភាពជំរុញ និងលើកទឹកចិត្តដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរខេត្ត និងវិស័យឯកជន ក្នុងការចូលរួមចំណែកបង្កើនទំហំពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរឲ្យបានដល់ ១៥ប៊ីលានដុល្លារអាមេរិកនៅឆ្នាំ២០២០ ស្របតាមគោលដៅដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលនៃប្រទេសទាំងពីរ។ កិច្ចប្រជុំគាំទ្រការធ្វើពាណិជ្ជកម្ម និងវិនិយោគតភ្ជាប់រវាងតំបន់សេដ្ឋកិច្ចពិសេសរបស់ប្រទេសទាំងពីរ ក្នុងខេត្តបន្ទាយមានជ័យ-ខេត្តស្រះកែវ និងខេត្តកោះកុង-ខេត្តត្រាត ដែលបានបម្រើប្រយោជន៍រួមដល់ប្រទេសទាំងពីរ។

៣-<u>ការតភ្ជាប់៖</u> កិច្ចប្រជុំស្វាគមន៍ចំពោះការតភ្ជាប់ផ្លូវដែកកម្ពុជាជាមួយផ្លូវដែកថៃ នៅចំណុចតភ្ជាប់ប៉ោយប៉ែត-អារញ្ញប្រាថេត កាលពីថ្ងៃ១៩ ខែកញ្ញា ឆ្នាំ២០១៦ និងវឌ្ឍនភាពនៃការសាងសង់ផ្លូវដែកពីក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ព្រះរាជាណាចក្រកម្ពុជា ទៅស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ ព្រះរាជាណាចក្រថៃ។ ភាគីទាំងពីរនឹងខិតខំជំរុញការសាងសង់ស្ពាននៅច្រកទ្វារព្រំដែនអន្តរជាតិព្រំ(ខេត្តប៉ៃលិន)-បានជាកាត(ខេត្តច័ន្ទបុរី) ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

៤-<u>កិច្ចសហប្រតិបត្តិការវិស័យកសិកម្ម៖</u> ដើម្បីជួយសម្រួល និងជំរុញការផ្លាស់ប្តូរកសិផលរវាងប្រទេសទាំងពីរ ភាគីទាំងពីរលើកទឹកចិត្តឲ្យខេត្តជាប់ព្រំដែននៃប្រទេសទាំងពីរពិភាក្សា និងសហការគ្នាសម្របសម្រួលដល់ការផ្លាស់ប្តូរពាណិជ្ជកម្ម ផលិតផលកសិកម្ម និងកសិផលរបស់ប្រជាពលរដ្ឋរស់នៅតំបន់ព្រំដែន។

៥-<u>កិច្ចសហប្រតិបត្តិការវិស័យការងារ៖</u> ភាគីទាំងពីរនឹងជំរុញដល់ក្រសួង ស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទាំងពីរ ឲ្យសហការគ្នាពន្លឿនការបំពេញបែបបទ និងនីតិវិធីស្របច្បាប់ជូនដល់ពលករកម្ពុជាដែលកំពុងធ្វើការនៅព្រះរាជាណាចក្រថៃឲ្យបានចប់សព្វគ្រប់ និងឆាប់រហ័ស ដើម្បីធានានូវសិទ្ធិស្នាក់នៅ និងបំពេញការងារដោយស្របច្បាប់របស់ពលករកម្ពុជានៅក្នុងព្រះរាជាណាចក្រថៃ ឱ្យបានឆាប់តាមតែអាចធ្វើបាន។ ភាគីទាំងពីរឯកភាពណែនាំដល់អាជ្ញាធរខេត្ត និងកងកម្លាំងមានសមត្ថកិច្ចនៃប្រទេសទាំងពីរ ឲ្យសហការគ្នាឲ្យបានជិតស្និទ្ធនៅក្នុងការបង្ការ ទប់ស្កាត់ និងឃាត់ខ្លួនមេខ្លោង ដែលបានបញ្ជូនពលករកម្ពុជាដោយខុសច្បាប់ឆ្លងកាត់ព្រំដែនចូលទៅព្រះរាជាណាចក្រថៃ។

៦-<u>ច្រកទ្វារព្រំដែន៖</u> ភាគីទាំងពីរបានឯកភាពជំរុញគណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោកកម្ពុជា-ថៃ(JBC)នៃប្រទេសទាំងពីរ កំណត់ពេលវេលាសមស្របដើម្បីធ្វើការវាស់វែងលម្អិតរួមគ្នានៅច្រកទ្វារតំបន់ព្រំដែនឆករកា(ស្រុកសំឡូត ខេត្តបាត់ដំបង)-បានម៉ាមួង(ស្រុកបរ៉ៃ ខេត្តត្រាត) មុនពេលអនុវត្តគម្រោងសាងសង់ផ្លូវថ្មី ដើម្បីជំរុញការតភ្ជាប់ការដឹកជញ្ជូន និងការសម្របសម្រួលការធ្វើពាណិជ្ជកម្ម។ ទន្ទឹមនេះ កិច្ចប្រជុំបានឯកភាពលើកទឹកចិត្តឲ្យខេត្តបន្ទាយមានជ័យ និងខេត្តស្រះកែវ ឲ្យបន្តកិច្ចពិភាក្សាគ្នាអំពីលទ្ធភាពនៃការបង្កើតច្រកទ្វារព្រំដែនថ្មី ស្ថិតនៅក្នុងភូមិព្រៃចាន់ ខេត្តបន្ទាយមានជ័យ និងភូមិណងម៉ាក់មូន ខេត្តស្រះកែវ។

៧-<u>ការគ្រប់គ្រងព្រំដែន៖</u> ភាគីទាំងពីរឯកភាពគ្នាថាប្រសិនបើមានវិវាទណាមួយកើតមានឡើងនៅតាមព្រំដែន ភាគីទាំងពីរគួរតែអត់ធ្មត់ឲ្យបានកម្រិតខ្ពស់បំផុត និងខិតខំទប់ស្កាត់វិវាទនោះកុំឲ្យរីករាលដាលធំឡើង ហើយប្រើប្រាស់គ្រប់មធ្យោបាយដើម្បីដោះស្រាយវិវាទនោះដោយសន្តិវិធី និងឲ្យបានឆាប់រហ័ស និងទាន់ពេលវេលា។ ប្រសិនបើបញ្ហាមិនត្រូវបានដោះស្រាយ ភាគីទាំងពីរគួររាយការណ៍ជូនថ្នាក់ដឹកនាំរៀងៗខ្លួន។ ភាគីទាំងពីរឯកភាពប្រគល់ភារកិច្ចឲ្យខេត្តជាប់ព្រំដែនបង្កើនកិច្ចសហប្រតិបត្តិការក្នុងការថែរក្សាបរិស្ថានរួមទាំងការលើកកម្ពស់ការគ្រប់គ្រងសំណល់រឹង និងរាវនៅតាមតំបន់ព្រំដែន។

៨-**ការតបណ្តាញអគ្គិសនី៖** ភាគីទាំងពីរលើកទឹកចិត្តឱ្យអាជ្ញាធរពាក់ព័ន្ធ ដើម្បីពិភាក្សាអំពីមធ្យោបាយក្នុងការជំរុញការតភ្ជាប់បណ្តាញអគ្គិសនីមកក្នុងតំបន់ជប់គគីរ(ខេត្តឧត្តរមានជ័យ)-តំបន់សៃតាគូ(ខេត្តបុរីរ៉ុំ) ផ្អែកតាមច្បាប់ និងបទដ្ឋានគតិយុត្តិរបស់ប្រទេសនីមួយៗ។

៩-**ការកាប់ឈើខុសច្បាប់៖** ភាគីទាំងពីរឯកភាពអនុវត្តច្បាប់សមស្របនៅក្នុងដោះស្រាយបញ្ហាកាប់ឈើខុសច្បាប់ តាមបណ្តោយព្រំដែនកម្ពុជា-ថៃ ជាមួយនឹងការអត់ធ្មត់ខ្ពស់បំផុត និងមិនប្រើប្រាស់អាវុធទប់ទល់នឹងអ្នកកាប់ឈើខុសច្បាប់។ ភាគីទាំងពីរឯកភាពបន្តអប់រំប្រជាពលរដ្ឋរបស់ខ្លួនបន្ថែមទៀត និងណែនាំដល់ប្រជាពលរដ្ឋអំពីផលវិបាកនៃការចូលរួមក្នុងសកម្មភាពជួញដូរផលិតផលព្រៃឈើខុសច្បាប់ ក៏ដូចជាការធ្វើជំនួញដែលមានផលប៉ះពាល់ទៅលើបរិស្ថាន។

១០-**ការបង្ការ ទប់ស្កាត់ និងការបង្ក្រាបបទល្មើស៖** ភាគីទាំងពីរវាយតម្លៃខ្ពស់ចំពោះអាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចនៅតាមបណ្តាខេត្តជាប់ព្រំដែននៃប្រទេសទាំងពីរដែលបានខិតខំប្រឹងប្រែងថែរក្សា និងការពារបានយ៉ាងល្អប្រសើរនូវសន្តិសុខ សណ្តាប់ធ្នាប់នៅតាមតំបន់ព្រំដែននៃប្រទេសទាំងពីរ ជាមួយនឹងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ និងឆាប់រហ័សនៅក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទនៅតាមតំបន់ព្រំដែន ដែលធានាបានយ៉ាងរឹងមាំនូវខឿនសន្តិភាព សន្តិសុខ និងស្ថិរភាពសង្គមនៅតាមតំបន់ព្រំដែននៃប្រទេសទាំងពីរ។

១១-**កិច្ចសហប្រតិបត្តិការវិស័យទេសចរណ៍៖** ភាគីទាំងពីរឯកភាពនឹងជំរុញការអនុវត្តផែនការសកម្មភាពទេសចរណ៍អេកម៉ិកឆ្នាំ២០១៦-២០១៨ និងជំរុញទេសចរណ៍បៃតង ប្រកបដោយការទទួលខុសត្រូវក្នុងសមាជិកប្រទេសអេកម៉ិក។

១២-**ទីក្រុងសម្ព័ន្ធមេត្រីភាព៖** ភាគីទាំងពីរគាំទ្រដល់ការបង្កើតទីក្រុង ឬខេត្តសម្ព័ន្ធមេត្រីភាពនៃប្រទេសទាំងពីរ ដោយលើកទឹកចិត្តឲ្យមានការទំនាក់ទំនង និងពិភាក្សាគ្នាលើការងារកិច្ចសហប្រតិបត្តិការលើវិស័យនានាដែលផ្តល់ផលប្រយោជន៍សម្រាប់ទីក្រុង និងខេត្តសម្ព័ន្ធមេត្រីភាពនៃប្រទេសទាំងពីរ។ កិច្ចប្រជុំបានអបអរសាទរចំពោះការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការបង្កើតខេត្តសម្ព័ន្ធភាពរវាង ខេត្តឧត្តរមានជ័យនិងខេត្តបុរីរ៉ាំ ខេត្តកំពង់ធំនិងខេត្តសុរិន្ទ នៅក្នុងឱកាសកិច្ចប្រជុំនេះ ដោយមានវត្តមានប្រធានគណៈប្រតិភូនៃប្រទេសទាំងពីរធ្វើជាសាក្សីក្នុងពិធីចុះហត្ថលេខានេះ។

១៣-**យន្តការសម្របសម្រួល៖** កិច្ចប្រជុំបានលើកទឹកចិត្តដល់អភិបាលខេត្ត ក្រុង ស្រុកជាប់ព្រំដែន ឲ្យជួបប្រជុំគ្នាជាប្រចាំដោយផ្លាស់ប្តូរគ្នាធ្វើជាម្ចាស់ផ្ទះម្តងម្នាក់ ក្នុងពេលវេលាសមស្របមួយដែលបានព្រមព្រៀងគ្នាដោយអភិបាលខេត្ត ក្រុង ស្រុកជាប់ព្រំដែននៃប្រទេសទាំងពីរ។

គណៈប្រតិភូថៃក៏បានសម្តែងនូវអំណរគុណដ៏ជ្រាលជ្រៅចំពោះភាគីកម្ពុជាដែលបានរៀបចំស្វាគមន៍ និងទទួលបដិសណ្ឋារកិច្ចយ៉ាងរាក់ទាក់ និងកក់ក្តៅបំផុតក្នុងអំឡុងពេលទស្សនកិច្ច ព្រមទាំងចាត់ចែងរៀបចំកិច្ចប្រជុំនេះបានយ៉ាងល្អប្រសើរ។

គណៈប្រតិភូកម្ពុជាបានសម្តែងការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះគណៈប្រតិភូថៃ ដែលបានផ្តល់កិច្ចសហការយ៉ាងជិតស្និទ្ធ និងល្អប្រសើរក្នុងការរៀបចំកិច្ចប្រជុំនេះឲ្យទទួលបានលទ្ធផលល្អ និងសម្រេចបាននូវគោលបំណងរួមក្នុងការពង្រឹងពង្រីកចំណងមិត្តភាព សាមគ្គីភាព ការយោគយល់គ្នា និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងខេត្តជាប់ព្រំដែន ដើម្បីជាប្រយោជន៍ដល់ប្រជាជាតិ និងប្រជាជននៃប្រទេសទាំងពីរ។

ភាគីទាំងពីរបានព្រមព្រៀងគ្នាថា កិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៧ នឹងប្រារព្ធធ្វើនៅព្រះរាជាណាចក្រថៃនាពេលវេលាសមស្របដែលមានការព្រមព្រៀងគ្នា។ កាលបរិច្ឆេទ និងទីកន្លែងនៃកិច្ចប្រជុំនឹងធ្វើការប្រាស្រ័យទាក់ទងគ្នាតាមរយៈការទូត។

*********